# ដំណាំម្រះរដូវវស្សា

Bitter gourd off season

## I. ការជ្រើសរើសពូជ

ម្រះជាប្រភេទដំណាំយកផ្លែ ដើមរបស់វា វារតោងឡើងច្រើង ឬ ជន្លង់ដែលអាចលូតលាស់បានប្រវែង ២,៥-៤,៥០ម ។ ពូជដែលកំពុងពេញនិយមលើទីផ្សារមានៈ



- ពូជក្បាលកោះ KK1
- ពូជនៅទីផ្សារមកពី អ៊ីស្តវ៉េស៊ីដ និង ពូជជាតៃ មកពីប្រទេសថៃ

## II. វិធីសាស្រ្តនៃការដាំដុះ

មុននិងធ្វើការដាំដុះត្រូវរៀបចំជាមុន ដូចជា រៀបចំដីថ្នាល បណ្តុះកូន

### ១- ការរៀបចំដីសំរាប់ដាំ

មុននឹងភ្ជួរដី ត្រូវរាស់ប្រមូលយកស្មៅចេញឱ្យស្អាត ភ្ជួរហាលដីឱ្យបានច្រើនដង យ៉ាងតិចចំនួនកន្លះខែមុននឹងលើករង ។ ក្រោយពីរាស់បំបែកដីឱ្យម៉ត់ កៀរដីឱ្យស្មើ លើករងឱ្យខ្ពស់តាមទិសជំរេលដី ងាយទឹកហូរបានលឿនពេលមានភ្លៀងធ្លាក់។ កំពស់រង ២៥-៣០ សម ទទឹងរង ១,២ម ប្រវែងរង ១០-៥០ម យកជីកំប៉ុស្ត ឬជីលាមកសត្វពុកលួ ចំនួន ៣ បង្គី ជី ១៥-១៥-១៥ ចំនួន ១៥០ង ជី 0.0.៤៦ ចំនួន ១០0g ជីទាំង ៣ ប្រភេទនេះមកបាចលាយគ្នាលើរង ហើយជ្រុំលប់ទៅក្នុងដីកៀររងឱ្យស្មើ ពង្រាបឱ្យហាប់គ្របគំរបកៅស៊ូគ្របដីឱ្យរួចស្រេច និងចោះរន្ធដាំជាពីរជួរ ចន្លោះជួរ ៦០ស.ម ចន្លោះគុម្ព ៤០ស.ម ។

### ២- ការបណ្តុះកូន និងដាំ

ដំបូងយកគ្រាប់ពូជម្រះមកដាក់ត្រាំងទឹកក្តៅអ៊ុនៗ រយៈពេល ២០នាទី ក្រោយមកដាក់ត្រាំទឹកធម្មតាមួយយប់ រួចលាងគ្រាប់ម្រះឱ្យស្អាតខ្ចប់នឹងក្រណាត់ស្អាតសើមៗដាក់ផ្អាប់ក្នុងធុងទឹកកករយៈពេល ២-៣ ថ្ងៃ ទើបយកទៅដាក់បណ្តុះកន្ទោង កញ្ច្រែង ស្បោង ។ បណ្តុះត្រូវដាក់បំពេញដោយដីផ្សំ ដុតសំលាប់មេរោគជាមុនឱ្យពេញ ៩០% បន្ទាប់មកទៀតយកគ្រាប់ម្រះ ដែលផ្អាប់រួចទៅដាក់ក្នុងកន្ទោង ឬកញ្ច្រែង ចំនួន មួយគ្រាប់ៗ ហើយបាចដីលប់គ្រាប់ឱ្យជិត គ្របចំបើងពីលើ ស្រោចទឹកឱ្យជោគភ្លាម ។ រយៈពេល ៤-៧ ថ្ងៃ ក្រោយបណ្តុះ កូនម្រះដុះពន្លកទូលដីចេញមក បកចំបើងនោះចេញភ្លាម



ពេលកូនម្រះលាស្លឹកកំណើតទាំងពីរ គឺពេលអាចយកទៅដាំបាន ។

របៀបដាំយកកូនម្រះទៅដាំតាមចន្លោះរន្ធកៅស៊ូគ្របទុកជាមុនមួយរន្ធមួយដើម ហើយស្រោចទឹកឱ្យជោគភ្លាមហាមទុកយូរក្រោយពីដាំ ហើយធ្វើឱ្យស្លឹកម្រះរួញមខ្លោចម្រះលូតលាស់យឺត ។

## III. ការថែទាំដំណាំម្រះ

ដើម្បីឱ្យម្រះទទួលបានទិន្នផលខ្ពស់ ត្រូវរៀបចំកម្មវិធីថែទាំឱ្យត្រូវទៅតាមវគ្គនៃការលូតលាស់ក្នុងនោះមាន:

### ១- ការស្រោចទឹក

ម្រះជាប្រភេទដំណាំត្រូវការទឹករាល់ថ្ងៃ តែវាមិនត្រូវការទឹកជោគជាំខ្លាំងនោះឡើយ ។ កាលណាសំណើមដីសើមខ្លាំងធ្វើឱ្យម្រះឆាប់ងាប់ដើម ។ ក្នុងករណីគ្មានភ្លៀង គេស្រោចទឹកព្រឹកល្ងាច ប៉ុន្តែបើមានភ្លៀងធ្លាក់ខ្លាំងត្រូវបង្ហូរទឹកចេញពីថ្នាលជាបន្ទាន់ ។ វគ្គដែលត្រូវការទឹកច្រើន គឺចាប់ពីម្រះចេញផ្កាឡើងទៅ ។

### ២- ការដកស្មៅ និងដាក់ជី

ក្រោយពីមានស្មៅដុះ ត្រូវដកស្មៅតាមរន្ធ គុម្ពម្រះ និងចន្លោះរងឱ្យស្អាត ហើយបន្តការដាក់ជីជាបន្តបន្ទាប់ ។ ម្រះត្រូវការជីកំប៉ុស្តិ៍ទឹកដែលត្រាំមានលាមកមាន់លាយជាមួយទឹកនោម ។ បរិមាណជី ២លីត្រ លាយជាមួយទឹក ១៨លីត្រ ស្រោចចំគុម្ពមួយអាទិត្យម្តង១ ។ ចំពោះការដាក់ជីគីមីវិញគេចែកការដាក់ចំនួន ៣ដង ជាបន្តបន្ទាប់១ ៖

- លើកទី១ ដាក់បំប៉នក្រោយដាំរយៈពេល ១៥ ថ្ងៃប្រភេទជីអ៊ុយរ៉េ ៥០ក្រាម ជី ១៥-១៥-១៥ ចំនួន ១០០ ក្រាម ជី ០.០.៤៦ ចំនួន ៥០ក្រាម លាយបញ្ចូលគ្នាដាក់ក្រោមកៅស៊ូគំរបតាមចន្លោះគុម្ព ។
- លើកទី២ បំប៉នក្រោយដាំរយៈពេល ៣០ថ្ងៃ ប្រើតែប្រភេទជី១៥-១៥-១៥ ទំងន់ ១០០ក្រាមមួយមុខគត់
- លើកទី៣ ករណីម្រះនៅតែចេញផ្កាបន្តការបន្ថែមជី ដូចលើកទី១ ប៉ុន្តែបរិមាណថយចុះបន្តិចដើម្បីឱ្យផ្លែម្រះលូតលាស់បានល្អរយៈពេល ៤៥ ថ្ងៃ ក្រោយដាំ ។

### ៣- ការដោតចំណារ ឬដាក់ឆ្នើ



ម្រះអាចវារតោងឡើងសំរះធ្នើ ឬចំណារ ដូចនេះគេត្រូវដោតចំណារមែកឈើក្រៀម១ ប្រវែង ២,៥០ម ឱ្យញឹកចងខ្ទាស់ឱ្យជាប់តាមគុម្ពនិមួយ១។ ក្រោយពីម្រះលូតលាស់បានស្លឹកចំនួន ៣ ។ដូចគ្នានេះដែរសំរាប់ផលិតកម្មធំ១ គ្មានសំរះ មែកឈើ គេប្រើសំណាញ់ចាក់ដោយនីឡុងក្រឡា ១០សម ទទឹង សំណាញ់ប្រវែង ៤ម បណ្តោយ ១០-៥ម គ្រាន់តែបោះង្គោលកំពស់ ២ម ចំនួន ៣-៤ បង្គោលចំ

កណ្តាលរងចងស្នូរកណ្តាលមួយឱ្យមាំ រួចយកសំណាញ់មកពាក់ពីលើ ហើយទំលាក់ជើងសំណាញ់ឱ្យជាប់ដីក្បែរគុម្ពម្រះធ្វើឱ្យម្រះវារតោងឡើងបានស្រួលក្រោយពីម្រះមានសន្លឹកចំនួន ៣ ដូចគ្នា ។

## IV. <u>**ការគ្រប់គ្រងជំងឺ សត្វល្អិត**</u>

### **១-វិធីសាស្ត្រគ្រប់គ្រងជំងឺ**




ម្រះច្រើនជួបការបំផ្លាញ ដោយជំងឺសំខាន់ៗ ពីរប្រភេទ នៅរដូវវស្សាជំងឺនេះ ច្រើនតែកើតឡើងក្នុងវគ្គម្រះពង្រីកផ្លែមុនប្រមូលផល គឺជំងឺទុំស្លឹក (Downy mildew) កើតលើស្លឹកក្បែរៗដីមុន ហើយរាលឡើងមកស្លឹកខាងលើបណ្តាលឱ្យក្តិបម្រះ លែងលូតលាស់ ។ ជំងឺមួយទៀតធ្វើឱ្យរលួយប្ញស និង គល់ ពេលសំណើមដីសើមខ្លាំង អាកាសធាតុក្តៅខ្លាំង ។ ក្រោយពីពិនិត្យឃើញជំងឺទាំងពីរនេះកើតឡើងនូវរោគសញ្ញា គេត្រូវបន្ថយការស្រោចទឹក ស្រោចជី ហើយយកថ្នាំការពារ ជំងឺផ្សិតប្រភេទ ម៉ាណែបស៊ីណែប ឬម៉ែនកូសែប មកលាយទឹកបាញ់ឱ្យជោគ ៥-៦ ថ្ងៃម្តង កំរិតប្រើ ២ ស្លាព្រាបាយ ឱ្យទឹក ១៥ លីត្រ ។

### **២- <u>វិធីសាស្ត្រគ្រប់គ្រងសត្វល្អិត</u>**

ម្រះរដូវវស្សាជួបការបំផ្លាញ ដោយសត្វល្អិតចង្រៃមួយចំនួនធំដូចជា:

**- មមាច ចៃ ពីងពាងក្រហម** កាលណាមមាចជញ្ជក់ស្លឹករស់នៅក្រោមស្លឹកច្រើនធ្វើឱ្យស្លឹកម្រះប្រែពណ៌ទៅជាលឿងហើយស្ងួត កាលណាមានពីងពាងក្រហមជញ្ជក់ស្លឹកធ្វើឱ្យស្លឹកខ្លោច ស្ងួត កាលណាមានចៃបំផ្លាញច្រើនធ្វើឱ្យ ម្រះរួញត្រួយ ....... ។ នៅពេលមានវត្តមានកត្តាចង្រៃទាំងនេះ ត្រូវអនុវត្តវិធានការណ៍កំចាត់ជាបន្ទាន់ ។

**- ដង្កូវមូរទ្រួយ** ដង្កូវប្រភេទនេះច្រើនរស់នៅក្នុងកញ្ចុំទ្រួយម្រះខ្ចីៗ វាស៊ីដាច់ស្លឹក ដាច់ត្រួយលែងលូតលាស់លឿនបាន គេត្រូវព្យាយាមពិនិត្យត្រួយខ្ចីៗ គ្រប់វគ្គលូតលាស់ ជាពិសេសវគ្គចេញផ្កាដំបូង ។ ក្រៅពីនោះទៀតដង្កូវនេះអាចស៊ីផ្លែម្រះធ្វើឱ្យផ្លែម្រះឆែប ឬ ដាច់ ។

វិធានការណ៍កំចាត់ ប្រើប្រភេទថ្នាំអាបាម៉ិចទីនលេខ ៥0 ចំនួន ៣0សេសេ លាយនឹងម្សៅ កាបារីល ២ស្លាបព្រាបាយទឹក ១៥-១៨លីត្រ បាញ់នៅម៉ោង ៣-៤ ល្ងាច ។

**-ស្រាំងទិច ឬរុយអុចផ្លែ** កសិករយើងច្រើនហៅច្រាំងទិចៗ តែតាមពិតវាមិនមែនច្រាំង ឬ ស្រាំងឡើយ វាជាប្រភេទរុយទិចផ្លែបញ្ចូលពងទៅក្នុងក្តិបនៃផ្លែម្រះ ក្រោយពីក្តិបនោះជ្រុះផ្កាខាងចុង រួចមកគឺក្តិបបន្តពូជហើយ ។ វិធីសាស្ត្រការពារមាន ពីរយ៉ាង គឺគេរុំផ្លែម្រះ និងស្បោងក្រដាស់កាសែត ឬ ដាក់អន្ទាក់ស្នេហ៍ទាក់យកមេរុយទៅកំចាត់ ចោល ។ ក្រៅពីនោះគេបាញ់ថ្នាំបង្អើរៗចន្លោះម៉ោង ៨ ទៅម៉ោង ១១ ព្រឹក ជាពេលមេរុយចេញបន្តពូជ ហើយទិចផ្លែម្រះ ។

## V. ការប្រមូលផល

ផ្លែម្រះដែលអាចប្រមូលយកទៅធ្វើជាបន្លែបាន នៅពេលផ្លែរបស់វាមានក្រឡារីកត្រង់ស្មើ ពណ៌បៃតងខ្ចីរលោងក្រោយពីដាំរយៈពេល ៤៥-៥០ ថ្ងៃ ផ្លែដំបូងអាចប្រមូលផលបាន ។ ម្រះប្រមូលផលរៀងរាល់ថ្ងៃ គេធ្វើឡើងចន្លោះម៉ោង ៧.៣០-១០.៣០នាទីព្រឹក គេប្រើកន្ត្រៃដៃ ឬកូនកាំបិតមុតកាត់ផ្តាច់ទងផ្លែហើយដាក់កញ្ជើ ដោយថ្នមៗ ។